**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**


ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..០៧៥.....សហវ.ក.ដអក.អអហ


# ប្រកាស
## ស្តីពី
## ការដាក់ឱ្យដំណើរការប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំង បំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលឱ្យស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៩ អនក្រ.បក ចុះថ្ងៃទី១១ មីនា ២០២៤ ស្តីពីអាករលើតម្លៃបន្ថែម
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានឃើញប្រកាសលេខ ៥៤២ សហវ.ប្រក ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីវិធាននិងនីតិវិធីនៃការអនុវត្តអាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានឃើញប្រកាសលេខ ៧២៣ សហវ.ប្រក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ ស្តីពីវិធាននៃការប្រើប្រាស់វិក្កយបត្រ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១._**

ប្រកាសនេះ មានគោលបំណងដាក់ឱ្យប្រើប្រាស់ជាផ្លូវការប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា "ហៅកាត់ថា **ប.វ.អ.**" ដើម្បីធានានូវការគ្រប់គ្រងដំណើរការ ត្រួតពិនិត្យ តាមដាន នៃប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព គណនេយ្យភាព។

**ប្រការ ២._**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់ប្រតិបត្តិការវិក្កយបត្រ នៃ **ប.វ.អ.** ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣._**

វាក្យសព្ទសំខាន់ៗដែលប្រើប្រាស់ក្នុងប្រកាសនេះត្រូវបានកំណត់និយមន័យ ដូចមានក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

**ប្រការ ៤._**

**អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល** នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រង ប្រតិបត្តិ ត្រួតពិនិត្យ និងតាមដាន **ប.វ.អ.** ដែលមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រង ប្រតិបត្តិ និងតាមដានដំណើរការ **ប.វ.អ.** ជាប្រចាំ
- សម្របសម្រួល និងផ្តល់ព័ត៌មានអំពីការចុះឈ្មោះចូលជាសមាជិកនៃ **ប.វ.អ.** ជូនភាគីដែលពាក់ព័ន្ធទាំងអស់
- ពិនិត្យ និងសម្រេចលើការស្នើសុំចូលជាសមាជិក **ប.វ.អ.** និងការស្នើសុំនានារបស់សមាជិក **ប.វ.អ.**
- ពិនិត្យ និងកែលម្អលើវិធាន និងនីតិវិធីនៃ **ប.វ.អ.** តាមការចាំបាច់
- សម្របសម្រួល និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសសម្រាប់ការតភ្ជាប់សន្ទានកម្មជាមួយប្រព័ន្ធនានា
- គ្រប់គ្រងទិន្នន័យសមាជិកភាព **ប.វ.អ.** ដោយធានាឱ្យបាននូវសុវត្ថិភាព ឯកជនភាព និងសុចរិតភាពទិន្នន័យ

- រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកម្មវិធីផ្សព្វផ្សាយនានាពាក់ព័ន្ធនឹង **ប.វ.អ.** ដើម្បីពង្រឹងសមត្ថភាព និងជំរុញការប្រើប្រាស់វិក្កយបត្រអេឡិចត្រូនិក
- រៀបចំគោលការណ៍ និងវិធានការផ្នែកសន្តិសុខសាយប័រ ដើម្បីការពារទិន្នន័យអ្នកប្រើប្រាស់ និងធានាឱ្យបាននូវអនុលោមភាពតាមបទប្បញ្ញត្តិនានា
- ធ្វើជាមជ្ឈមណ្ឌលទំនាក់ទំនងសម្រាប់ **ប.វ.អ.** ក្នុងការផ្តល់ព័ត៌មានបច្ចុប្បន្នភាពរបស់ **ប.វ.អ.** និងទទួលមតិ ឬ សំណូមពរនានាពាក់ព័ន្ធនឹង **ប.វ.អ.**
- ផ្តល់ការគាំទ្រជាប្រចាំដល់សមាជិក **ប.វ.អ.** ក្នុងពេលប្រតិបត្តិការ **ប.វ.អ.**
- សហការជាមួយភាគីពាក់ព័ន្ធដែលជាក្រសួង ស្ថាប័ន ឬអង្គភាពរដ្ឋ ក្នុងការជំរុញការធ្វើបរិវត្តកម្មឌីជីថល និងការសម្រួលនីតិវិធីនានាដែលជាប្រយោជន៍សម្រាប់ធុរជន និងសាធារណជន
- អភិវឌ្ឍ នវានុវត្ត និងកែលម្អជាប្រចាំទៅលើមុខងារ និងសមត្ថភាពរបស់ **ប.វ.អ.**
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ ៥._**

**ប.វ.អ.** គឺជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់រដ្ឋ ដែលមានតួនាទីជាប្រព័ន្ធកណ្តាលសម្រាប់ផ្លាស់ប្តូរវិក្កយបត្រក្នុងទម្រង់ជាអេឡិចត្រូនិករវាងភាគីអ្នកលក់ ឬ អ្នកផ្តល់សេវា និងភាគីអ្នកទិញ ឬ អ្នកទទួលសេវា។ ប្រព័ន្ធនេះ ក៏មានមុខងារក្នុងការផ្តល់អត្តសញ្ញាណ និងបញ្ជាក់ទទួលស្គាល់វិក្កយបត្រអេឡិចត្រូនិកជាផ្លូវការដោយមិនតម្រូវឱ្យមានការបោះពុម្ពវិក្កយបត្រជាក្រដាសទៀតឡើយ។

**ប្រការ ៦._**

វិក្កយបត្រអេឡិចត្រូនិក គឺជាវិក្កយបត្រដែលបានបញ្ជូនក្នុងទម្រង់ជាអេឡិចត្រូនិកឆ្លងកាត់ការពិនិត្យ និងផ្តល់អត្តសញ្ញាណជាវិក្កយបត្រអេឡិចត្រូនិកដោយ **ប.វ.អ.**។

វិក្កយបត្រអេឡិចត្រូនិកនេះ ត្រូវបានទទួលស្គាល់ជាភស្តុតាង និងជាកំណត់ត្រាទម្រង់ឌីជីថល ដែលមានសុពលភាព និងអានុភាពគតិយុត្ត ដោយអនុលោមតាមបទប្បញ្ញត្តិគតិយុត្តជាធរមាន។

វិក្កយបត្រអេឡិចត្រូនិកនេះ នឹងត្រូវរក្សាទុកជាកំណត់ត្រាទម្រង់ឌីជីថលរយៈពេល ១០ (ដប់) ឆ្នាំ សម្រាប់ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ និងបញ្ជាក់ភាពដើមនៃវិក្កយបត្រ ក្នុងករណីផ្លូវច្បាប់ចាំបាច់តែប៉ុណ្ណោះ។

វិក្កយបត្រអេឡិចត្រូនិកនេះ អាចប្រើប្រាស់បានដោយសមាជិកនៃ **ប.វ.អ.** ចាប់ពីការចូលជាធរមាននៃប្រកាសនេះ។

**ប្រការ ៧._**

សមាជិកនៃ **ប.វ.អ.** ត្រូវបានចែកចេញជា២ (ពីរ) ប្រភេទ រួមមាន៖ សមាជិកជាអ្នកប្រើប្រាស់ និងសមាជិកជាអ្នកផ្គត់ផ្គង់ប្រព័ន្ធ។

សមាជិកជាអ្នកប្រើប្រាស់ សំដៅដល់ភាគីអ្នកលក់ ឬ ភាគីអ្នកផ្តល់សេវា និងភាគីអ្នកទិញ ឬ ភាគីអ្នកទទួលសេវា។ ភាគីអ្នកលក់ ឬ ភាគីអ្នកផ្តល់សេវា គឺជាអ្នកបង្កើត និងបញ្ជូនវិក្កយបត្រអេឡិចត្រូនិក។ ភាគីអ្នកទិញ ឬ ភាគីអ្នកទទួលសេវា គឺជាអ្នកទទួលវិក្កយបត្រអេឡិចត្រូនិក។

សមាជិកជាអ្នកផ្គត់ផ្គង់ប្រព័ន្ធ សំដៅដល់ក្រុមហ៊ុន ឬ ស្ថាប័នដែលជាអ្នកផ្គត់ផ្គង់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលត្រូវភ្ជាប់សន្ធានកម្មជាមួយ **ប.វ.អ.** ដើម្បីធ្វើអន្តរប្រតិបត្តិការជាមួយប្រព័ន្ធរបស់សមាជិកដែលជាអ្នកផ្គត់ផ្គង់ប្រព័ន្ធទាំងអស់។

វិធាន និងនីតិវិធីនៃការចូលជាសមាជិក **ប.រ.អ.** ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។ សមាជិកនៃ **ប.រ.អ.** ត្រូវគោរព និងអនុវត្តតាមវិធាន និងនីតិវិធីនេះ។

**ប្រការ ៨._**

បុគ្គលដែលមិនមែនជាសមាជិក **ប.រ.អ.** ប្រើប្រាស់ **ប.រ.អ.** ដើម្បីធ្វើសកម្មភាពណាមួយដោយពុំមានការអនុញ្ញាតពីអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ រាល់សកម្មភាពដែលផ្ទុយនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃ ព្រះរាជាណាចក្រកម្ពុជានឹងត្រូវទទួលទោសអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៩._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១០._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៩រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមករា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១**

**នៃប្រកាសលេខ** ០៧៥ សហវ.ប្រក.អពន្ធ **ចុះថ្ងៃទី** ២២ **ខែ** មករា **ឆ្នាំ** ២០២៥

**ស្តីពី**

**ការដាក់ឱ្យដំណើរការប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា**

## សន្ទានុក្រម

**ក**

**ក្រុមហ៊ុនផ្គត់ផ្គង់ប្រព័ន្ធ** គឺជាក្រុមហ៊ុនឯកជន ដែលផ្គត់ផ្គង់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលមានមុខងារបង្កើតវិក្កយបត្រសម្រាប់ក្រុមហ៊ុនផ្គត់ផ្គង់ទំនិញ និងសេវាកម្ម ឬ ស្ថាប័នផ្សេងៗ។

**វ**

**វិក្កយបត្រ** មានពីរប្រភេទគឺ វិក្កយបត្រអាករ និងវិក្កយបត្រធម្មតា។

**វិក្កយបត្រអាករ** មាននិទ្ទេសដូចតទៅ៖

- ឈ្មោះសហគ្រាស អាសយដ្ឋាន និងលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់អ្នកលក់ឬអ្នកផ្គត់ផ្គង់
- លេខរៀងវិក្កយបត្រតាមលំដាប់ និងកាលបរិច្ឆេទចេញវិក្កយបត្រ
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកទិញ ព្រមទាំងលេខអត្តសញ្ញាណកម្មសារពើពន្ធ
- សេចក្តីបរិយាយមុខទំនិញឬសេវា បរិមាណ និងថ្លៃ
- តម្លៃសរុបនៃប្រភេទទំនិញនីមួយៗដែលមិនទាន់គិតអាករនានា
- ប្រាក់អាករនីមួយៗ (ករណីទំនិញឬសេវាត្រូវជាប់អាករពិសេស អាករសម្រាប់បំភ្លឺសាធារណៈ ឬ/និង អាករលើការស្នាក់នៅ) និងអាករលើតម្លៃបន្ថែម
- ហត្ថលេខា និងឈ្មោះរបស់អ្នកលក់និងអ្នកទិញ (ចំពោះអ្នកទិញដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និងសម្រាប់វិក្កយបត្រក្រដាស)។

**វិក្កយបត្រធម្មតា** មាននិទ្ទេសដូចតទៅ៖

- ឈ្មោះសហគ្រាស អាសយដ្ឋាន និងលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់អ្នកលក់ឬអ្នកផ្គត់ផ្គង់
- លេខរៀងវិក្កយបត្រតាមលំដាប់ និងកាលបរិច្ឆេទចេញវិក្កយបត្រ
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកទិញ
- សេចក្តីបរិយាយមុខទំនិញឬសេវា បរិមាណ និងថ្លៃ
- តម្លៃរួមបញ្ចូលទាំងអាករនានានៃទំនិញនីមួយៗ
- ហត្ថលេខា និងឈ្មោះរបស់អ្នកលក់ (សម្រាប់វិក្កយបត្រក្រដាស)។

**ស**

**សន្ទានកម្ម** គឺជាច្រកចេញចូលស្តង់ដារដែលអនុញ្ញាតឱ្យទិន្នន័យអាចផ្លាស់ប្តូរពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយ ទៅប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយផ្សេងទៀត។

**អ**

**អន្តរប្រតិបត្តិការ** គឺជាសមត្ថភាពនៃប្រព័ន្ធឌីជីថល ដែលអាចធ្វើសន្ទានកម្មជាមួយគ្នាក្នុងការផ្លាស់ប្តូរ និងការប្រើប្រាស់ទិន្នន័យ ដែលជាទូទៅកើតឡើងដោយស្វ័យប្រវត្តិតាមលក្ខខណ្ឌកំណត់។

**អ្នកលក់ ឬ អ្នកផ្តល់សេវា** គឺជាអ្នកផ្គត់ផ្គង់ទំនិញ ឬ សេវាទៅកាន់អ្នកទិញ ឬ អ្នកទទួលសេវា និងមានកាតព្វកិច្ចបង្កើត និងបញ្ជូនវិក្កយបត្រទៅកាន់អ្នកទិញ ឬ អ្នកទទួលសេវា។

**អ្នកទិញ ឬ អ្នកទទួលសេវា** គឺជាអតិថិជន ឬ អ្នកទទួលផលទំនិញ ឬ សេវាពីអ្នកលក់ ឬ អ្នកផ្តល់សេវា និងមានកាតព្វកិច្ចទទួលវិក្កយបត្រពីប្រតិបត្តិការនោះ។

## ឧបសម្ព័ន្ធទី២

នៃប្រកាសលេខ ០៧៥ សហវ.ប្រក ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០២៥

ស្ដីពី

## ការដាក់ឱ្យដំណើរការប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា

## វិធាន និងនីតិវិធី នៃការចូលជាសមាជិក